# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អធិដ្ឋានសម្រាប់ការត្រាស់ហៅនៅព្រះសហគមន៍សន្តយ៉ូសែប
# ផ្សារតូច ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩
# សាងសង់ជីវិតលើព្រះយេស៊ូ

**អត្ថបទទី១៖ អេសាយ ២៦,១-១៦**

ចូរបើកទ្វារឲ្យប្រជាជាតិដ៏សុចរិត ដែលមានចិត្តស្មោះស្ម័គ្រចូលផង!។ អស ២៦,២

**ដំណឹងល្អ៖ ម៉ាថាយ ៧,២១.២៤-២៧**

អ្នកណាស្ដាប់ពាក្យខ្ញុំនេះ ហើយប្រព្រឹត្តតាម អ្នកនោះប្រៀបបានទៅនឹងមនុស្សឈ្លាសវៃម្នាក់ ដែលបានសង់ផ្ទះរបស់ខ្លួននៅលើផ្ទាំងថ្ម។ មថ ៧,២៤

បងប្អូនជាទីស្រឡាញ់!

គួរឲ្យយើងចាប់អារម្មណ៍អំពីព្រះបន្ទូលរបស់ព្រះយេស៊ូ "**អ្នកចូលនៅក្នុងព្រះរាជ្យនៃស្ថានបរមសុខ មិនមែនជាអ្នកដែលគ្រាន់តែហៅខ្ញុំថាព្រះអម្ចាស់ ព្រះអម្ចាស់ប៉ុណ្ណោះទេ**"។ ជូនកាលយើងគិតថា ដើម្បីភ្ជាប់ជាមួយព្រះជាម្ចាស់ ដើម្បីរស់នៅជាមួយព្រះជាម្ចាស់អស់កល្បជានិច្ច យើងគ្រាន់តែអធិដ្ឋានទូលអង្វរព្រះជាម្ចាស់ សូមព្រះជាម្ចាស់ជួយយើងខ្ញុំផងល្មមហើយ។ ប៉ុន្តែថ្ងៃនេះក្នុងអត្ថបទនេះបានបញ្ជាក់ច្បាស់ណាស់ថា ប្រសិនបើយើងចង់ភ្ជាប់ជាមួយព្រះជាម្ចាស់គឺយើងត្រូវតែធ្វើតាមព្រះហឫទ័យរបស់ព្រះបិតា ដែលគង់នៅស្ថានបរមសុខនោះវិញ។ ទោះបីយើងចូលអភិបូជា យើងអធិដ្ឋាន យើងស្ដាប់ព្រះបន្ទូល និងទូលអង្វរព្រះយេស៊ូសូមអាណិតយើងមិនទាន់ល្មមទេ យើងត្រូវការគិតពិចារណា **តើខ្ញុំដែលជាគ្រីស្តបរិស័ទ ដែលជាបុត្រាបុត្រីរបស់ព្រះជាម្ចាស់ ខ្ញុំធ្វើដូចម្ដេចដើម្បីរស់នៅតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់?**

តាមពិតព្រះយេស៊ូបានណែនាំឲ្យយើងភ្ជាប់ជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ នៅថ្ងៃដែលយើងទទួលពិធីជ្រមុជទឹកយើងបានចូលនៅក្នុងទឹក គឺយើងបានចូលយ៉ាងពេញលក្ខណៈនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះវិញ្ញាណដ៏វិសុទ្ធ ជាព្រះប្រាជ្ញាញាណរបស់ព្រះជាម្ចាស់ពីមួយថ្ងៃទៅមួយថ្ងៃបំភ្លឺជីវិតរបស់យើងឲ្យយើងចូលនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់។ **តើយើងធ្វើដូចម្ដេចដើម្បីស្គាល់គម្រោងការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតខ្ញុំ? តើយើងធ្វើដូចម្ដេចដើម្បីចូលនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានរៀបចំទុកសម្រាប់ជីវិតរបស់ខ្ញុំ?** យើងជឿថា យើងពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ ព្រះសហគមន៍កាតូលិកយើងរស់នៅក្នុងឥទ្ធពលនៃមហាសន្និបាតវ៉ាទីកង់ទីពីរ ដែលបានកសាងរបៀបដែលយើងរស់នៅសព្វថ្ងៃនៅក្នុងព្រះសហគមន៍។ នៅឆ្នាំ១៩៦២ពេលក្រុមលោកកាឌីណាល់ បានជ្រើសរើសសម្ដេចប៉ាបថ្មី គឺ សម្ដេចប៉ាប យ៉ូហានទី២៣ ដែលមានអាយុ៧៨ឆ្នាំហើយ។ ព្រះវិញ្ញាណដ៏វិសុទ្ធបានបំភ្លឺសម្ដេចប៉ាប យ៉ូហានទី២៣

ហើយព្រះអង្គឲ្យព្រះសហគមន៍របស់យើងត្រូវការបើកទ្វារ ព្រះអង្គបានហៅលោកអភិបាលទាំងអស់នៅក្នុងពិភពលោក ដើម្បីរៀបចំប្រជុំដើម្បីចូលនៅក្នុងដំណើរជាមួយព្រះវិញ្ញាណដ៏វិសុទ្ធ ធ្វើឲ្យព្រះសហគមន៍មានរបៀបថ្មីដើម្បីរស់នៅក្នុងសង្គមបច្ចុប្បន្ននេះ។

យើងត្រូវការអាន យើងត្រូវការមើលសញ្ញាណសម្គាល់ដែលមានបច្ចុប្បន្ននេះ ដើម្បីទទួលព្រះវិញ្ញាណដ៏វិសុទ្ធមកសម្រុះសម្រួលនៅក្នុងជីវិតយើង។ ឆ្នាំនេះ យើងគោរពខួប៥០ឆ្នាំដែលក្រុមលោកអភិបាលនៅទ្វីបអាស៊ីបានជួបជុំគ្នា ចង់ឲ្យយើងដែលជាប្រជាជាតិអាស៊ីធ្វើដំណើររួមជាមួយគ្នា។ ឲ្យយើងបើកភ្នែក ដើម្បីមើលឃើញបញ្ហាដែលយើងមានសព្វថ្ងៃនៅក្នុងសង្គមយើង ដោយបម្រើអ្នកក្រីក្រ បង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសាសនានានា ឲ្យយើងប្រកាសដំណឹងល្អនៅក្នុងវប្បធម៌។ ពេលយើងធ្វើដំណើរដូចនេះ បន្តិចម្តងៗយើងចូលនៅក្នុងគម្រោងការរបស់ព្រះជាម្ចាស់ នៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធដើម្បីគិត **តើនៅខាងមុខនេះ ព្រះជាម្ចាស់មានគម្រោងការអ្វីខ្លះសម្រាប់ព្រះសហគមន៍កាតូលិកកម្ពុជាយើង ដើម្បីឲ្យយើងបន្តប្រកាសដំណឹងល្អដល់ប្រជាជាតិអាស៊ី ជាពិសេសដល់ប្រជាជនកម្ពុជា?** តាមរយៈការបម្រើអ្នកក្រីក្រ តាមទំនាក់ទំនងជាមួយសាសនានានា និងការប្រកាសដំណឹងល្អនៅក្នុងវប្បធម៌របស់យើង។

យើងត្រូវការទុកឲ្យព្រះវិញ្ញាណដ៏វិសុទ្ធធ្វើដំណើរ ព្រះយេស៊ូបានណែនាំឲ្យយើងរៀបចំជីវិតរបស់យើងជាគ្រីស្តបរិស័ទ ដោយយកមូលដ្ឋានគ្រឹះយ៉ាងរឹងមាំដែលយើងមានគឺព្រះយេស៊ូផ្ទាល់។ មានតែព្រះជាម្ចាស់ដែលនៅស្ថិតស្ថេរ និងអាចណែនាំឲ្យយើងអាចឆ្លងគ្រប់ឧបសគ្គដើម្បីឆ្លើយតបដល់គម្រោងការរបស់ព្រះជាម្ចាស់គ្រប់ពេលវេលា។ ព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យយើងទៅជាមនុស្សឈ្លាសវៃ ដែលសាងសង់ជីវិតរបស់យើងលើផ្ទាំងថ្មដ៏រឹងមាំគឺព្រះយេស៊ូផ្ទាល់។ យើងមិនតែទូលអង្វរសុំ ប៉ុន្តែប្រសិនបើយើងចង់ឲ្យព្រះបិតាឆ្លើយតបពាក្យទូលអង្វររបស់យើង យើងត្រូវតែសាងសង់ជីវិតរបស់យើងលើព្រះបិតាផ្ទាល់។ ប្រសិនបើយើងមិនដែលសាងសង់ជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃលើព្រះជាម្ចាស់ យើងចេះតែសុំប្រហែលឥតមានផលផ្លែទេ។

យើងអធិដ្ឋាន សម្រាប់ព្រះសហគមន៍របស់យើងដែលកំពុងធ្វើដំណើរថែមទៀតនៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីឲ្យយើងចាក់ឫសនៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់យ៉ាងពិតប្រាកដមែន។ រដូវរង់ចាំ ជាពេលវេលាមួយដើម្បីអធិដ្ឋាន ដើម្បីស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដើម្បីបើកភ្នែក **តើវត្តមានរបស់ព្រះជាម្ចាស់សព្វថ្ងៃនៅកន្លែងណានៃសង្គមរបស់យើង? តើព្រះជាម្ចាស់ទន្ទឹងរង់ចាំអ្វីខ្លះពីខ្ញុំ?** យើងដឹងថាព្រះជាម្ចាស់យាងមក ដើម្បីណែនាំឲ្យមនុស្សតូចតាច ណែនាំឲ្យមនុស្សដែលគ្មានសេចក្តីសង្ឃឹមមានសេចក្តីសង្ឃឹមនិងទទួលជីវិតថ្មី។ នៅក្នុងរដូវរង់ចាំនេះ ឲ្យយើងបើកភ្នែកដើម្បីមើលឃើញសេចក្តីត្រូវការរបស់បងប្អូន ឲ្យគេរកឃើញជីវិតនៅក្នុងគម្រោង

ការដ៏អស្ចារ្យ  ឲ្យយើងធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គដើម្បីចូលនៅក្នុងស្ថានបរមសុខ  នាថ្ងៃអនាគត។ អាម៉ែន៕